# គម្រោងវិវឌ្ឍនាការកសិអេកូឡូស៊ី និង ប្រព័ន្ធស្បៀងអាហារសុវត្ថិភាព [ASSET]

## បរិបទ

ប្រព័ន្ធកសិកម្មនៅតំបន់អាស៊ីអាគ្នេយ៍ស្ថិតនៅលើផ្លូវបំបែករវាងប្រពលវប្បកម្ម តាមទម្លាប់ និងប្រពលវប្បកម្មតាមកសិអេកូឡូស៊ីដែលកំពុងរីកសាយ។ ការបន្តធ្វើប្រពលវប្បកម្មតាមទម្លាប់ ដែលពឹងផ្អែកយ៉ាងខ្លាំងលើធាតុចូលគីមី និងដើមទុនខ្ពស់ បានកំពុងធ្វើអោយមាន ឯកវប្បកម្មនៃផែនទេសភាពកសិកម្ម ការសឹករិចរិលដី និងការបាត់បង់ជីវៈចម្រុះ ហើយធ្វើអោយកើនឡើងហានិភ័យដល់សុខភាពកសិករ និងអ្នកបរិភោគ។ លើសពីនេះ ក្រៅពីសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ការព្រួយបារម្ភពីសុវត្ថិភាពស្បៀងកំពុងតែកើនឡើង ជាពិសេសពាក់ព័ន្ធនឹងសំណល់ថ្នាំគីមីដែលមានកម្រិតខ្ពស់ និងការបំពុលដី និងទឹកក្រោមដី។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ កសិអេកូឡូស៊ីបង្កើននវានុវត្តន៍ផ្នែកបច្ចេកទេសកសិកម្ម និងទីផ្សារ ឆ្ពោះទៅកាន់ការធ្វើកសិកម្មដែលមាននិរន្តរភាព ភាតរភាពចំពោះបរិស្ថាន និងប្រកបដោយសុខភាព។

5 ឆ្នាំ

2020 - 2025

ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម

15 លាន អ៊ឺរ៉ូ ផ្តល់ដោយទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសបារាំង (AFD) សហភាពអឺរ៉ុប (EU) និង មូលនិធិបារាំងសម្រាប់បរិស្ថានសកល (FFEM)

## ការពិពណ៌នា

គោលបំណងជារួមនៃ**គម្រោងវិវឌ្ឍនាការកសិអេកូឡូស៊ី និង ប្រព័ន្ធស្បៀងអាហារសុវត្ថិភាព (គម្រោង ASSET)** គឺធ្វើឲ្យប្រព័ន្ធកសិកម្ម និងស្បៀងអាហារក្នុងតំបន់កាន់តែមាននិរន្តរភាព កាន់តែមានសុវត្ថិភាព និងកាន់តែមានបរិយាបន្ន តាមរយៈការរួមបញ្ចូលសក្តានុពលនៃកសិអេកូឡូស៊ី។ គម្រោងនេះត្រូវបានអនុវត្តដោយអង្គការGRET ដែលជាអ្នកសម្របសម្រួលទូទៅ ដោយសហការយ៉ាងជិតស្និតជាមួយ CIRAD ដែលទទួលបន្ទុកជាអ្នកសម្របសម្រួលវិទ្យាសាស្ត្រ រួមជាមួយនឹងសម្ព័ន្ធដៃគូដែលជាអង្គការ-ស្ថាប័នជាតិ អឺរ៉ុប អន្តរជាតិចំនួន 20 និង ទីភ្នាក់ងារអង្គការសហប្រជាជាតិ ចំនួន 2។

**គម្រោង ASSET** នឹងបង្កើត និងជំរុញចក្ខុវិស័យរួមនៃវិវឌ្ឍនាការកសិអេកូឡូស៊ី និង ប្រព័ន្ធស្បៀងអាហារសុវត្ថិភាព (ASSET) តាមរយៈមធ្យោបាយដ៏ទូលំទូលាយដែលរួមបញ្ចូលនូវការស្រាវជ្រាវ ការបង្កើតបណ្តាញ ការតស៊ូមតិគោលនយោបាយ ការអភិវឌ្ឍសមត្ថភាព ការបង្កើនការយល់ដឹង និងទំនាក់ទំនងដោយប្រើប្រាស់បណ្តាញ **ALiSEA**[1]។ សម្ព័ន្ធដៃគូនឹងចូលរួមជាមួយរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងកសិករខ្នាតតូច ដើម្បីផលិត និងប្រើប្រាស់ចំណេះដឹងទៅបង្កើតដំណើរការនវានុវត្តន៍ប្រកបដោយនិរន្តរភាព និងគោលនយោបាយថ្មីៗដែលមានសារៈសំខាន់ចំពោះយុវវ័យ និងសមភាពយេនឌ័រ។

**គម្រោង** ASSET នឹងគាំទ្រដល់ការបើកកិច្ចសន្ទនាក្នុងការផ្សារភ្ជាប់ការផ្លាស់ប្តូរកសិកម្ម និងទីផ្សារនៅក្នុងក្រមខ័ណ្ឌគោលនយោបាយនៅកម្រិតមូលដ្ឋាន កម្រិតជាតិ និងកម្រិតតំបន់ តាមរយៈកម្មវិធីធ្វើបង្ហាញ (Flagship Program) ដែលលើកកម្ពស់នវានុវត្តន៍ផ្នែកបច្ចេកទេស ផ្នែកអង្គភាព និងផ្នែកស្ថាប័ននៅកម្រិតដែនដីដើម្បីបង្កើតភ័ស្តុតាងដ៏រឹងមាំពីលទ្ធផល និងផលប៉ះពាល់នៃនវានុវត្តន៍ទាំងនោះ តាមរយៈការពង្រីកការផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវការអនុវត្តជោគជ័យផ្សេងៗ និងតាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន និងសកម្មភាពផ្តួចផ្តើមនានាថ្នាក់តំបន់។







1. *បណ្តាញកសិអេកូឡូស៊ីនៅអាស៊ីអាគ្នេយ៍ https://ali-sea.org/ for more information*

*រូបភាពពី៖ Lucie Reynaud, Estelle Biénabe, Mélanie Blanchard*

## មធ្យោបាយ

ជាមួយនឹងមធ្យោបាយដ៏ទូលំទូលាយ គម្រោងនឹងដាក់ឲ្យដំណើរការយ៉ាងសកម្មនូវកត្តាជំរុញផ្សេងៗសម្រាប់វិវឌ្ឍនាការកសិអេកូឡូស៊ី និង ប្រព័ន្ធស្បៀងអាហារសុវត្ថិភាព នៅក្នុងវិស័យសំខាន់បីដែលមានទំនាក់ទំនងគ្នា។




## រចនាសម្ព័ន្ធ

### ផ្នែកទី 1៖ ការចូលរួមពហុភាគីពាក់ព័ន្ធក្នុង ASSET ដោយផ្តោតលើផលប៉ះពាល់

**អនុផ្នែក 1.1:**
ការពង្រឹងបណ្តាញ ALiSEA តាមរយៈការបង្កើតបណ្តាញ និងចែករំលែកចក្ខុវិស័យរួមនៃASSET

**អនុផ្នែក 1.2:**
ការផ្លាស់ប្តូរទម្រង់នៃការផ្សព្វផ្សាយរបស់ ALiSEA ទៅជាមជ្ឈមណ្ឌលចំណេះដឹង

**អនុផ្នែក 1.3:**
ការជំរុញ ASSET តាមរយៈការអភិវឌ្ឍសមត្ថភាព ការទំនាក់ទំនង និងសកម្មភាពផ្សព្វផ្សាយ

### ផ្នែកទី 2៖ ការពង្រីកនវានុវត្តន៍កសិអេកូឡូស៊ី និងសុវត្ថិភាពស្បៀងអាហារពីកម្រិតមូលដ្ឋានទៅកាន់កម្រិតតំបន់

**អនុផ្នែក 2.1:**
ការផលិតចំណេះដឹង និងការគាំទ្រនវានុវត្តន៍

**អនុផ្នែក 2.2:**
ក្របខ័ណ្ឌវិធីសាស្ត្រសម្រាប់វាយតម្លៃលទ្ធផល និងផលប៉ះពាល់នៃនវានុវត្តន៍ និងវិវឌ្ឍនាការ

**អនុផ្នែក 2.3:**
ការសន្ទនា និងការតស៊ូមតិគោលនយោបាយដោយផ្អែកលើភស្តុតាង

## វិធីសាស្ត្រ

គម្រោងនឹងបង្កើតក្របខ័ណ្ឌវិធីសាស្ត្រដែលមានមូលដ្ឋានទូលំទូលាយរួមមួយដើម្បី៖

1) សហផលិតជាមួយពហុភាគីពាក់ព័ន្ធនូវចក្ខុវិស័យរួម និងមាគ៌ានៃផលប៉ះពាល់ដែលអាចទុកចិត្តបាន ហើយមានទំនាក់ទំនងគ្នាសម្រាប់ ASSET នៅកម្រិតទីតាំងបង្ហាញ កម្រិតជាតិ និងកម្រិតតំបន់ ដោយប្រើប្រាស់វិធីសាស្ត្រទ្រឹស្តីនៃការផ្លាស់ប្តូរ (ToC)

2) វាយតម្លៃ និងតាមដានការអនុវត្ត និងផលប៉ះពាល់នៃនវានុវត្តន៍ និងវិវឌ្ឍនាការរបស់ ASSET និងកំណត់លក្ខខណ្ឌជំរុញផ្សេងៗ

3) ធ្វើផែនការ និងសម្របសកម្មភាពស្រាវជ្រាវនៅទីតាំងបង្ហាញកម្រិតដែនដីតាមរយៈការការរៀនសូត្រ និងដកស្រង់បទពិសោធន៍ពីការងារអនុវត្តន៍ និងពីគ្នាទៅវិញទៅមក។

ដំណើរការនៃការបង្កើតយុទ្ធសាស្ត្រផ្សេងៗតាមរយៈឧបករណ៍នៃវិធីសាស្ត្រToCដើម្បីឈានដល់ការបង្កើតចក្ខុវិស័យរួមសម្រាប់ ASSET ពីកម្រិតមូលដ្ឋានដល់កម្រិតតំបន់នឹងជួយផ្លាស់ប្តូរបណ្តាញ ALiSEA ទៅជាសម្ព័ន្ធបើកចំហនៃអង្គការកសិករ អ្នកបង្កើតគោលនយោបាយ ប្រតិបត្តិករក្នុងច្រវាក់តំលៃ អ្នកស្រាវជ្រាវ និងអ្នកអភិវឌ្ឍន៍ធ្វើការរួមគ្នាតាមមាគ៌ានៃផលប៉ះពាល់ឆ្ពោះទៅការសម្រេចចក្ខុវិស័យរួម។

ការបង្កើតចំណេះដឹងថ្មីៗពីកម្រិតមូលដ្ឋានដល់កម្រិតតំបន់នឹងចូលរួម ហើយក៏ត្រូវបានជំរុញផងដែរតាមរយៈកិច្ចសន្ទនាគោលនយោបាយពហុភាគីពាក់ព័ន្ធដែលអនុវត្តន៍ពីកម្រិតមូលដ្ឋានតាមរយៈកម្មវិធីធ្វើបង្ហាញ កម្រិតជាតិ និងទៅដល់កម្រិតតំបន់ (អាស៊ាន)។

## ផលប៉ះពាល់ & លទ្ធផល

### ផលប៉ះពាល់រយៈពេលវែង

ការកើនឡើងនូវសន្តិសុខស្បៀង និងសុវត្ថិភាពស្បៀង សម្រាប់កសិករខ្នាតតូច និងសហគ្រាសខ្នាតតូច-មធ្យម នៅតំបន់អាស៊ីអាគ្នេយ៍។

### ផលប៉ះពាល់រយៈពេលមធ្យម

ការផ្លាស់ប្តូរជាមូលដ្ឋានសម្រាប់ការទទួលស្គាល់ និងការអនុវត្តគោលការណ៍កសិអេកូឡូស៊ី និងសកម្មភាពនានាក្នុងគោលនយោបាយ និងសង្គមដើម្បីចជំរុញវិវឌ្ឍនាការប្រព័ន្ធសុវត្ថិភាពស្បៀងអាហារ។

ការបង្កើតអោយមានគំរូផ្សេងៗនៃពិពិធកម្មផលិតកម្ម និងទីផ្សារដោយបង្កើនការផ្សារភ្ជាប់តាមមធ្យោបាយផ្សេងៗទៅនឹងការនាំចេញ និងខ្សែច្រវាក់តំលៃក្នុងស្រុក និងប្រព័ន្ធសុវត្ថិភាពស្បៀងអាហារ។

### លទ្ធផល

- ALiSEA ក្លាយជាបណ្តាញដែលគ្រប់គ្រងដោយសមាជិកស្វយ័តពេញលេញ
- ALiSEA ក្លាយជាមជ្ឈមណ្ឌលចំណេះដឹងសំខាន់មួយស្តីពីវិវឌ្ឍនាការ
- ភាគីពាក់ព័ន្ធប្រើប្រាស់ចំណេះដឹង និងសមត្ថភាពថ្មីៗដែលបានទទួលដើម្បីគាំទ្រវិវឌ្ឍនាការ
- ភាគីពាក់ព័ន្ធបង្រីក នវានុវត្តន៍ និងគំរូផ្សេងៗ ដែលបានសាកល្បងពីកម្រិតមូលដ្ឋាន ដល់កម្រិតតំបន់
- អ្នកបង្កើតគោលនយោបាយបញ្ចូលចំណេះដឹងដើម្បីជំរុញការផ្លាស់ប្តូរឆ្ពោះទៅវិវឌ្ឍនាការ

*ការកំណត់ពីផលប៉ះពាល់ និងលទ្ធផលខាងនេះ មធ្យោបាយនៃគម្រោង ASSET ផ្អែកលើការសន្មត់ចំនួន២ជាមូលដ្ឋាន៖*

- ការសន្មត់ទី ១៖ ពង្រឹងសមត្ថភាព និងបង្កើនចំណេះដឹងនិងភាពជាម្ចាស់នៃភាគីពាក់ព័ន្ធគោលដៅដើម្បីជួយអោយពួកគេផ្លាស់ប្តូរទៅវិវឌ្ឍនាការកសិអេកូឡូស៊ី និងប្រព័ន្ធស្បៀងអាហារសុវត្ថិភាព។
- ការសន្មត់ទី ២៖ ផ្តល់នូវភស្តុតាងនៅពហុកម្រិតពីលទ្ធផល និងផលប៉ះពាល់ពហុវិស័យនៃការអនុវត្តកសិអេកូឡូស៊ីក្នុងប្រព័ន្ធស្បៀងអាហារសុវត្ថិភាពដើម្បីជួយដល់ពហុភាគីពាក់ព័ន្ធអាចគាំទ្រ និងអនុវត្តន៍ការផ្លាស់ប្តូរឆ្ពោះទៅវិវឌ្ឍនាការជាប្រព័ន្ធ។





*រូបភាពពី៖ Estelle Biénabe, Mélanie Blanchard*




## ទីតាំងធ្វើបង្ហាញ (Flagship site)

ទីតាំងធ្វើបង្ហាញគឺជាដែនដីរដ្ឋបាលសាកល្បង ដែលប្រមូលផ្តុំកិច្ចខិតខំប្រឹងប្រែង និង ធនធានា នាដើម្បីគាំទ្រ និងចងក្រងជាឯកសារពីវិវឌ្ឍនាការកសិអេកូឡូស៊ី និងប្រព័ន្ធស្បៀងអាហារសុវត្ថិភាព។

គម្រោង ASSET នឹងគាំទ្រនវានុវត្តន៍ និងការផលិតចំណេះដឹងថ្មីនៅទីតាំងធ្វើបង្ហាញចំនួន៤ ដោយប្រទេសគោលដៅមួយ មានទីតាំងមួយ។

**Marie** Christine Lebret អ្នកសម្របសម្រួលទូទៅ
lebret@gret.org

**Estelle Biénabe** អ្នកសម្របសម្រួលវិទ្យាសាស្ត្រ
estelle.bienabe@cirad.fr

**Mélanie Blanchard** អ្នកសម្របសម្រួលវិទ្យាសាស្ត្រ
melanie.blanchard@cirad.fr

ដៃគូថ្នាក់ជាតិ៖ 9 • ដៃគូអឺរ៉ុប៖ 10 • ទីភ្នាក់ងារអង្គការសហប្រជាជាតិ៖ 2 • ដៃគូអន្តរជាតិ៖ 3

## ម្ចាស់ជំនួយ

## អ្នកសម្របសម្រួល

## PARTNERS

*ឯកសារនេះត្រូវបានផលិតឡើងដោយជំនួយហិរញ្ញវត្ថុពីទីភ្នាក់ងារអភិវឌ្ឍបារាំង (AFD) សហភាពអឺរ៉ុប (EU) និងមូលនិធិបារាំងសម្រាប់បរិស្ថានសកល (FFEM)។ ទស្សនៈដែលបានបង្ហាញនៅក្នុងឯកសារនេះមិនអាចយកមកឆ្លុះបញ្ចាំងទស្សនៈផ្លូវការរបស់ AFD EU និងFFEM បានឡើយ។*